Washington State Department of
CHILDREN, YOUTH & FAMILIES

# លិខិតជូនដំណឹង និងការយល់ព្រមចំពោះការត្រួតពិនិត្យ

**គោលបំណង៖** ផ្តល់ជូនលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់មាតាឬបិតាក្នុងករណីស្នើសុំការត្រួតពិនិត្យ និងដើម្បីទទួលបានការយល់ព្រមពីមាតាបិតា ដើម្បីអនុវត្តការត្រួតពិនិត្យ។

| ឈ្មោះកូន | ថ្ងៃខែឆ្នាំកំណើត | អ្នកសម្របសម្រួលធនធានគ្រួសារ |
|---|---|---|
| | | |

## មូលហេតុចំពោះលិខិតដំណឹង

កម្មវិធី ESIT តម្រូវឱ្យផ្តល់ជូនលោកអ្នកនូវលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដែលមានរយៈពេលសមរម្យ មុនការអនុវត្តសកម្មភាពត្រួតពិនិត្យ (ការកំណត់អត្តសញ្ញាណ)។ ការណ៍នេះតម្រូវឱ្យលោកអ្នកផ្តល់ជូនការយល់ព្រមជាលាយលក្ខណ៍អក្សរដែលបានជូនដំណឹងសម្រាប់សកម្មភាពទាំងនេះតាមរយៈការហត្ថលេខារបស់អ្នកខាងក្រោម។ គោលបំណងនៃការត្រួតពិនិត្យនេះ គឺដើម្បីកំណត់តម្រូវការរបស់កូនអ្នកសម្រាប់ការវាយតម្លៃ/ការប៉ាន់ប្រមាណដែលស្ថិតក្រោមកម្មវិធី ESIT ។ ហើយនេះជារបាយការណ៍របស់អ្នកអំពីលិខិតជូនដំណឹងនោះ។

*"ការយល់ព្រម" មានន័យថាthat; (1) (1) លោកអ្នកទទួលបានដំណឹងយ៉ាងពេញលេញអំពីព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងសកម្មភាព ដែលក្នុងនោះការយល់ព្រមណាមួយត្រូវបានស្វែងរកជាភាសាកំណើតរបស់អ្នក ឬរបៀបនៃការប្រាស្រ័យទាក់ទង ដែលរួមមានទាំងភាសាប្រើសញ្ញា អក្សរសម្រាប់មនុស្សខ្វាក់ ឬការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ដែលសមស្រប; (2) ដែលលោកអ្នកយល់ដឹងនិងយល់ព្រមជាលាយលក្ខណ៍អក្សរចំពោះការអនុវត្តសកម្មភាពដែលត្រូវបានស្វែងរក; (3) ការយល់ព្រមនេះពិពណ៌នាអំពីសកម្មភាពនិងរាយបញ្ជីកត់ត្រាអន្តរាគមន៍ចាប់ផ្តើមដំបូង (ប្រសិនបើមាន) ដែលនឹងត្រូវបញ្ចេញឱ្យដឹងព័ត៌មានទៅអ្នកណាដែលត្រូវផ្សព្វផ្សាយឱ្យដឹង; និង (4) ការផ្តល់ជូនការយល់ព្រមរបស់អ្នកជាការស្ម័គ្រចិត្ត ហើយអាចដកចេញវិញដោយសរសេរជាលាយលក្ខណ៍អក្សបានគ្រប់ពេលវេលា។ ប្រសិនបើលោកអ្នកដកចេញការយល់ព្រមនោះ វាមិនមានសកម្មភាពឡើងវិញឡើយ6 (វាមិនអនុវត្តចំពោះសកម្មភាពដែលបានកើតឡើងមុនការយល់ព្រមនេះត្រូវបានដកចេញវិញឡើយ) ។*

## វិធានការដែលបានស្នើសុំ

កូនរបស់អ្នកនឹងត្រូវត្រួតពិនិត្យនៅក្នុងផ្នែកវិវត្តន៍មួយឬច្រើនដូចខាងក្រោមនេះ៖ ការចងចាំ ចលនាដៃជើងនិងរាងកាយ ជំនាញប្រើដៃ ការប្រាស្រ័យទាក់ទង សង្គម-អារម្មណ៍ ការសម្របសម្រួលខ្លួន ចក្ខុឬការមើលឃើញ និងការស្តាប់ឬការឮ។ លទ្ធផលត្រួតពិនិត្យនេះ នឹងត្រូវប្រើប្រាស់ដើម្បីកំណត់តម្រូវការរបស់កូនអ្នកសម្រាប់ការវាយតម្លៃ/ការប៉ាន់ប្រមាណដែលស្ថិតក្រោមកម្មវិធី ESIT ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើលោកអ្នកស្នើសុំ និងផ្តល់ជូនការយល់ព្រមចំពោះការវាយតម្លៃគ្រប់ពេលវេលានៅក្នុងដំណើរការត្រួតពិនិត្យនោះ ការវាយតម្លៃនឹងត្រូវធ្វើឡើង ទោះជាកូនរបស់អ្នកមិនសង្ស័យថាមានពិការភាពក៏ដោយ។ លទ្ធផលនិងព័ត៌មានដែលទទួលបាននៅអំឡុងពេលត្រួតពិនិត្យនោះ នឹងរក្សាការសម្ងាត់។

## ការពិពណ៌នា

របៀបត្រួតពិនិត្យនេះត្រូវអនុវត្តដោយផ្អែកលើការប្រែប្រួលទៅតាមតម្រូវការរបស់កូនអ្នក។ ការត្រួតពិនិត្យនេះអាចរាប់បញ្ចូលការពិនិត្យឡើងវិញនូវកំណត់ត្រាវេជ្ជសាស្ត្រ/ការលូតលាស់ ការសម្ភាសន៍មាតាឬបិតា ការអង្កេតមើលកុមារ និង/ឬ ការគ្រប់គ្រងវិធីសាស្ត្រត្រួតពិនិត្យមើលការលូតលាស់ផ្លូវការនិងក្រៅផ្លូវការ។ បុគ្គលិកដែលអនុវត្តការត្រួតពិនិត្យ នឹងពិភាក្សាជាមួយលោកអ្នកអំពីវិធីសាស្ត្រនិងលទ្ធផលទាំងនេះ។

## ការកំណត់ពេលវេលា

ប្រសិនបើមានការសម្រេចមួយបានធ្វើឡើងថាកូនរបស់អ្នកត្រូវការការវាយតម្លៃ/ការប៉ាន់ប្រមាណ និងការអភិវឌ្ឍផែនការសេវាកម្មក្រុមគ្រួសារដែលមានលក្ខណៈបុគ្គល (IFSP) ត្រូវតែបញ្ចប់ក្នុងរយៈពេល 45 ថ្ងៃនៃថ្ងៃប្រតិទិនដោយគិតចាប់ពីថ្ងៃដែលកូនរបស់អ្នកបានបញ្ជូនទៅកម្មវិធី ESIT ។ ប្រសិនបើគ្រួសាររបស់អ្នកត្រូវការពេលបន្ថែមលើសពី 45 ថ្ងៃនោះ វាមានសារៈសំខាន់ណាស់ដែលថាលោកអ្នកត្រូវប្រាប់អ្នកសម្របសម្រួលធនធានក្រុមគ្រួសាររបស់អ្នក។

*កំណត់កាលបរិច្ឆេទកូនរបស់អ្នក ដែលបានបញ្ជូនទៅកម្មវិធី ESIT៖* ____________

## ការទទួលស្គាល់ និងរបាយការណ៍អំពីការយល់ព្រម

ខ្ញុំបាទ/នាងខ្ញុំបានទទួលឯកសារថតចម្លងមួយច្បាប់នៃសិទ្ធិនិងការការពារសុវត្ថិភាពតាមនីតិវិធីរបស់ខ្ញុំ ដែលស្ថិតក្រោមផ្នែក C នៃ IDEA (កម្មវិធីគាំទ្រកុមារនិងទារកចាប់ផ្ដើមដំបូង *ច្បាប់ស្ដីពីការអប់រំបុគ្គលដែលមានពិការភាព (IDEA) ផ្នែក C ការការពារតាមនីតិវិធី [សិទ្ធិមាតាឬបិតា]}*
ដោយមានលិខិតជូនដំណឹងនេះ។____________________________________________________

*អក្សរដំបូងនៃឈ្មោះមាតាឬបិតា*

សិទ្ធិទាំងនេះត្រូវបានពន្យល់ដល់ខ្ញុំ ហើយខ្ញុំបាទ/នាងខ្ញុំយល់ដឹងអំពីសិទ្ធិទាំងនេះ។ ខ្ញុំបាទ/នាងខ្ញុំ យល់ថាការយល់ព្រមរបស់ខ្ញុំជាការស្ម័គ្រចិត្ត ហើយថាខ្ញុំអាចជ្រើសរើសមិនឱ្យត្រួតពិនិត្យកូនខ្ញុំបានគ្រប់ពេលវេលា បើទោះជាក្រោយពីការចុះហត្ថលេខាលើសំណុំបែបបទនេះក៏ដោយ។
ខ្ញុំបាទ/នាងខ្ញុំយល់ថាប្រសិនបើខ្ញុំជ្រើសរើសមិនព្រមយល់ព្រមចំពោះការត្រួតពិនិត្យនេះ កូនរបស់ខ្ញុំនឹងមិនត្រូវត្រួតពិនិត្យឡើយ។
ខ្ញុំបាទ/នាងខ្ញុំយល់ថាខ្ញុំអាចស្នើសុំការវាយតម្លៃកូនរបស់ខ្ញុំនៅពេលណាមួយនៅអំឡុងពេលមានដំណើរការត្រួតពិនិត្យ ហើយការវាយតម្លៃនឹងត្រូវធ្វើឡើង។

| | |
|---|---|
| ☐ ខ្ញុំផ្ដល់ជូន ☐ ខ្ញុំមិនផ្ដល់ជូន ការយល់ព្រមដែលបានជូនដំណឹងរបស់ខ្ញុំចំពោះកម្មវិធី ESIT ដើម្បីអនុវត្តសកម្មភាពនា ដែលបានពិពណ៌នាខាងលើ។ | |
| **សរសេរអក្សរពុម្ពឈ្មោះរបស់មាតាឬបិតា** | |
| **ហត្ថលេខាមាតាឬបិតា** | **កាលបរិច្ឆេទ** |

កុម្ភៈ 2012

| | |
|---|---|
| **បានទទួលដោយឈ្មោះ/ឋានៈ/ទីភ្នាក់ងារ** | **កាលបរិច្ឆេទ** |

ឯកសារភ្ជាប់ ; កម្មវិធីគាំទ្រកុមារនិងទារកចាប់ផ្ដើមដំបូង *ច្បាប់ស្ដីពីការអប់រំបុគ្គលដែលមានពិការភាព (IDEA) ផ្នែក* C *ការការពារសុវត្ថិភាពតាមនីតិវិធី {សិទ្ធិមាតាបិតា])*

កំណត់សម្គាល់*មាតាបិតាដែលត្រូវទទួលបាន ឯកសារថតចម្លងមួយច្បាប់ពីសំណុំបែបបទនេះ និងឯកសារថតចម្លងដែលមានចុះហត្ថលេខា ត្រូវរាប់បញ្ចូលក្នុងកំណត់ត្រាអន្តរាគមន៍ចាប់ផ្ដើមដំបូងរបស់កុមារ។*

កុម្ភៈ 2012